## វិទ្យាស្ថានស្រាវជ្រាវកិច្ចការសង្គមកម្ពុជា (ASRIC)
## សហការជាមួយ Asian/Pacific/American Institute at New York University

***សូមជូន***

# វេទិកាពិភាក្សាអំពីការរងទុក្ខរួមគ្នានិងជំនះឧបសគ្គរួមគ្នា

## ការរងគ្រោះដោយអំពើយង់ឃ្នងនៃខ្មែរក្រហម  កាកសំណល់ឈឺចាប់  និងដំណោះស្រាយរួមគ្នា

**ថ្ងៃសៅរ៍ ទី១៣ ខែធ្នូ ឆ្នាំ២០០៨ នៅក្រុង Lowell ពីម៉ោង៩:០០ព្រឹក ដល់ម៉ោង៧:០០ល្ងាច**

**សាលប្រជុំ O'Leary Auditorium, University of Massachusetts Lowell**

**510 O'Leary Library @ 61 Wilder Street, Lowell, Massachusetts**

របបខ្មែរក្រហមដែលបានត្រួតត្រាប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ បានកាប់សម្លាប់ប្រជាជនខ្មែរយ៉ាងរង្គាល អស់ជាងពីរលាននាក់ ក្នុងចំណោមប្រជាជនទាំងអស់ប្រមាណ៧លាននាក់ តាមរយៈការធ្វើទារុណកម្ម ការបង្អត់អាហារ និងការប្រហារជីវិត ។ ទោះបីរបបនេះបានកន្លងផុតទៅជិត៣០ឆ្នាំហើយក៏ដោយ ក៏កាកសំណល់ឈឺចាប់ដែលបន្សល់ទុកពីរបបនេះ នៅតែបន្តប៉ះពាល់ដល់ជីវិតប្រជាជនខ្មែរទាំងពីរជំនាន់សព្វថ្ងៃនេះ ក្នុងពេលដែលពួកគេកំពុងពុះពារជំនះក្តីរន្ធត់ពីអតីតកាល ដើម្បីសាងជីវិតសាជាថ្មី ស្តារស្មារតីខ្លួននិងព្រលឹងជាតិឡើងវិញ ប្រកបដោយភាពស្និតស្នាញ និងក្តីមោទនៈ ។ **វេទិកាពិភាក្សាអំពីការរងទុក្ខរួមគ្នានិងជំនះឧបសគ្គរួមគ្នា**នេះ មានរយៈពេលពេញមួយថ្ងៃ ដែលមានកម្មវិធីសំខាន់ៗ ដូចជា ÷

- ការថ្លែងប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកនៅរស់ជំនាន់ទីមួយនិងជំនាន់ទីពីរ
- ការផ្តល់ពត៌មានពីសំណាក់អ្នកសិក្សាស្រាវជ្រាវនិងអ្នកឯកទេស អំពីប្រវត្តិសាស្រ្តថ្មីៗនៅកម្ពុជា និងអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានបង្កើតឡើងរួមគ្នាដោយរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ
- ការបញ្ចាំងភាពយន្ត អំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយមានការបង្ហាញពីដំណើរការកាត់ក្តីជនឧក្រិដ្ឋពីជំនាន់ខ្មែរក្រហម
- ការសន្ទនាជាចំហក្នុងចំណោមអ្នកចូលរួមនិងអ្នកឯកទេសផ្សេងៗ បន្ទាប់ពីកម្មវិធីមួយវគ្គៗ

*នេះជាវេទិកាសាធារណៈដែលឥតគិតថ្លៃ ! សូមអញ្ជើញចូលរួមអោយបានកុះករ !*

*សូមចុះឈ្មោះឬទាក់ទងវិទ្យាស្ថានASRIC នៅcontact@asric-cambodia.org !*